ព្រះរាជាណាចក្រ កម្ពុជា

*Kingdom Of Cambodia*

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

Land Appraisal and Valuation Committee

លេខ ០០៦ សសរ.សហវ.ពដ

លិខិតចូល
ថ្ងៃទី 20 ខែមិថុនា ឆ្នាំ 2006

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០០៦

# សេចក្តីសំរេច
## ស្តីពី
## ការកែប្រែសមាសភាពអនុគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ខេត្តសៀមរាប

---

### ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៧០៤.១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២-នស-៩៤ ចុះថ្ងៃទី ២០ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកម-០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១-នស-៩៤ ចុះថ្ងៃទិ ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤
- បានឃើញច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស-រកម-០២៩៧-០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ១៩៩៧
- បានឃើញអនុក្រឹត្យលេខ ៥៨-អនក្រ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ២២៤ ប្រក-សហវ-ពដ ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

- បានឃើញសេចក្តីសំរេចលេខ ០០៤-សសរ-សហវ-ពដ ចុះថ្ងៃទ២៤ ខែសីហា ឆ្នាំ១៩៩៨ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ៣៩៣ ប្រក-សហវ-ពដ ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ១៩៩៩ ស្តីពីការកែប្រែសមាសភាពគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
- បានឃើញសេចក្តីសំរេចលេខ ០០១ សហវ.ពដ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
- បានឃើញសំណើរបស់អភិបាលខេត្តសៀមរាបលេខ ២៨៤ សណ ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០០៦ ស្តីពីសុំកែសំរួលសមាសភាពអនុគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ឱ្យបានត្រឹមត្រូវតាមមុខនាទីបច្ចុប្បន្ន ។
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅខេត្តសៀមរាប ។

## សំរេច :

**ប្រការ១:** សមាសភាពនៃអនុគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់នៅខេត្តសៀមរាប ដែលមាននៅក្នុងសេចក្តីសំរេចលេខ ០០១ សហវ.ពដ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ត្រូវបានកែប្រែដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម ស៊ូ ភិរិន្ទ | អភិបាលខេត្តសៀមរាប | ជាប្រធាន |
| ២- លោក ប៊ុន ថាឫទ្ធិ | នាយខុទ្ទកាល័យសាលាខេត្ត | ជាអនុប្រធាន |
| ៣- លោក ទី សុផាត | ប្រធានសាខាពន្ធដាខេត្ត | ជាអនុប្រធាន |
| ៤- លោក លួន អាន | ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់និងសុរិយោដីខេត្ត | ជាសមាជិក |
| ៥- លោក ណម ពិសិដ្ឋ | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | ជាសមាជិក |
| ៦- លោក តាត ប៊ុនឈឿន | ប្រធានមន្ទីរកសិកម្មខេត្ត | ជាសមាជិក |
| ៧- លោក ព្រំ សាម៉ន | អគ្គលេខាធិការរងទី១សាលាខេត្ត | ជាសមាជិក |

**ប្រការ២:** អនុគណៈកម្មការមានភារៈកិច្ច :

- ផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បង្កើតបញ្ជីដីត្រូវជាប់ពន្ធតាមតំបន់ក្នុងខេត្ត-ក្រុង
- លើកតំរោងតម្លៃដីក្នុងមួយម៉ែត្រក្រឡា គិតតាមតំបន់នីមួយៗក្នុងខេត្ត-ក្រុង ដើម្បីជាមូលដ្ឋានគណនាប្រាក់ពន្ធដាក់ជូនគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ពិនិត្យនិងសំរេច
- ផ្តល់មតិចំពោះរឿងវិវាទនានា ដែលពាក់ព័ន្ធទៅនិងដីមិនប្រើប្រាស់ ។

**ប្រការ៣:** អនុគណៈកម្មការអាចរៀបចំបង្កើតក្រុមជំនួយការមួយ ដើម្បីធានានិរន្តរភាពក្នុងប្រតិបត្តិការរបស់អនុគណៈកម្មការ ។

**ប្រការ៤:** សមាជិកអនុគណៈកម្មការ ត្រូវចូលរួមធ្វើការងារនិងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានអនុគណៈកម្មការ ។

**ប្រការ៥:** អនុគណៈកម្មការត្រូវចូលរួមធ្វើការងារនិងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានគណៈកម្មការនិងត្រូវរាយការណ៍ជាប្រចាំតាមខែនិមួយៗ មកគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ៦:** ឯកឧត្តម អស់លោក-លោកស្រី ដូចមានរាយនាមក្នុងប្រការ១ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារៈកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រធានគណៈកម្មការដោះស្រាយតំលៃដីមិនបានប្រើប្រាស់**

ចន់ វិបុល

**រដ្ឋលេខាធិការទី១ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាបជាពត៌មាន"
- ដូចប្រការ៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ